# Living the Lotus

## Buddhism in Everyday Life

8
2025
VOL. 239





## Rissho Kosei-kai of Hawaii Hosts Bon Dance Festival on July 11–12



Living the Lotus
Vol. 239 (August 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# “សរសើរ” តែម្យ៉ាងគត់

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ដើម្បីបណ្តុះបណ្តាលមនុស្ស

ខ្ញុំព្រះករុណាអាត្មាភាពបានអានសៀវភៅរបស់អប់រំវិទូជាច្រើនដែលក្នុងចំណោមនោះមានវិទូពីររូបដែលមានទស្សនៈរួមគ្នា។គឺអ្នកទាំងពីរមានទស្សនៈថាការទេសនាស្តីប្រដៅមនុស្សមិនមែនជាការអប់រំទេ។គំនិតរបស់អ្នកទាំងពីរគឺថាដែលហៅថាការអប់រំគឺ”ការសរសើរ”។វិទូម្នាក់ក្នុងចំណោមពីរនាក់នោះគឺលោកសាស្ត្រាចារ្យម៉ូរីណូប៊ឺ ហ្សូបានសរសេរថាគ្រូបង្រៀនឬអ្នកអប់រំបើកមាត់ពេលណា បញ្ចេញពាក្យពេលណា ត្រូវបញ្ចេញតែពាក្យសរសើរតែប៉ុណ្ណោះបានហើយ។

ឧទាហរណ៍ នៅពេលដែលឃើញសិស្សដាក់ស្បែកជើងរប៉ាត់រប៉ាយក្នុងធ្នើជាថ្នាក់ៗសម្រាប់ដាក់ស្បែកជើង គ្រូត្រូវតម្រង់តម្រៀបឱ្យត្រឹមត្រូវជំនួសសិស្សនៅពេលដែលសិស្សមិននៅទីនោះ។ការងារនោះគឺជាការងាររបស់គ្រូ។បើធ្វើបែបនេះស្បែកជើងរបស់សិស្សនឹងតម្រង់តម្រៀបយ៉ាងរៀបរយបន្តិចម្តងៗ។ពេលនោះទើបគ្រូសរសើរសិស្សថាមានរបៀបរបបណាស់។នេះទើបហៅថាការអប់រំនិងការណែនាំឬការដឹកនាំមនុស្ស។

យវិញទៀតលោកសាស្ត្រាចារ្យហៀវ៉ាសាវ៉ា ខូដែលជាអតីតសាកលវិទ្យាធិការសាកលវិទ្យាល័យក្យូតុបានសរសេរថាដែលហៅថាការអប់រំគឺ”ការសិក្សាស្រាវជ្រាវពីការសរសើរដៃគូរបស់ខ្លួន ហើយអ្វីដែលសំខាន់បំផុតគឺការផ្តល់ទៅដល់ដៃគូនូវសេចក្តីសប្បាយរីករាយសេចក្តីក្លាហាននិងសេចក្តីសង្ឃឹម។ពោលគឺលោកអធិប្បាយពីអត្ថន័យនៃការសរសើរ (អត្ថបទដែលមានចំណងជើងថា”ថ្ងៃនេះក៏ត្រូវតែសប្បាយនឹងរស់” ចុះក្នុង”ទស្សនាវត្តីជីចជី”)

ខ្ញុំព្រះករុណាអាត្មាភាពតែងតែនិយាយម្តងហើយម្តងទៀតពីសារសំខាន់នៃការបណ្តុះបណ្តាលមនុស្ស។គឺថាត្រូវដាំបណ្តុះមនុស្សឱ្យមានសមានចិត្តចំពោះអ្នកដទៃ។។ត្រូវបំពេញបេះដូងមនុស្សដែលជាទំពាំងស្ពងឬស្សីឱ្យមានទឹកដម។ពីព្រោះថាភាពស្រស់ត្រកាលនៃបេះដូងរបស់មនុស្សម្នាក់ៗនឹងការពារថែរក្សាភពផែនដីដ៏វិចិត្រហើយវាបន្តផ្សាប់ទៅនឹងភាពសុខដុំរមនានិងសុភមង្គលនៃអ្វីៗគ្រប់យ៉ាង។ដូចដែលលោកសាស្ត្រាចារ្យជំនាញខាងការអប់រំលោកបាននិយាយយោលទៅតាមទស្សនវិជ្ជានិងសាសនាហើយថាការកសាងមនុស្សគឺការសរសើរតែម្យ៉ាងគត់។

សាស្ត្រាចារ្យហៀវ៉ាសាវ៉ាបានសរសេរថា ”នៅកន្លែងដែលអ្នកខ្លួនឯងមិនដឹង នៅក្នុងបេះដូងរបស់អ្នកមានបង្កប់នូវអ្វីដ៏ប្រសើរជាង៩-១០ដង ដូច្នេះអ្នកត្រូវតែមានទំនុកចិត្តលើខ្លួនឯងហើយធ្វើអ្វីៗដោយមិនចាំបាច់ក្រែងចិត្តអ្នកណាឡើយ។”ប្រសិនបើពាក្យសរសើរខាងលើនេះជាពាក្យដែលមានន័យអប់រំគឺមានន័យថាការកសាងមនុស្សគឺការធ្វើឱ្យអ្នកនោះភ្ញាក់រលឹកពីធាតុព្រះពុទ្ធរបស់គេហើយការសរសើរមនុស្សគឺជាការជឿជាក់ទៅលើធាតុព្រះពុទ្ធរបស់អ្នកនោះ។

## ជឿហើយគោរព

ក៏ប៉ុន្តែនៅក្នុងជីវភាពពិតៗការសរសើរជាការលំបាកក្រៃលែង។ជំនួសការសរសើរមនុស្សចាស់ច្រើនតែស្ដីបន្ទោសឬរអ៊ូរទាំដាក់ក្មេងឬដៃគូនោះជាការពិត។ដូចដែលពាក្យទំនឹមជប៉ុនថែងមកដែរថា”ហួសពីខែ៩ឱ្យទៅច្រូតស្រូវសាលីតើបានផលអ្វីទៅ?ផ្ដល់យោបល់ដល់កូនអាយុលើសពី២០គេមិនស្ដាប់យើងទេ”។គឺមានន័យថាយើងអាចស្ដីប្រដៅកូនបានត្រឹមតែនៅពេលដែលគេមានអាយុ២-៣ឆ្នាំប៉ុនណោះ លើសតែពីនេះជាពិសេសនៅពេលដែលកូនចូលដល់វ័យជាមនុស្សពេញវ័យហើយ ប្រសិនបើពាក្យស្ដីប្រដៅនោះវាមិនមែនជាពាក្យដែលជ្រាបចូលទៅក្នុងបេះដូងគេទេគេស្ដាប់ពាក្យយើងមិនឮទេ។

ដូច្នេះតើត្រូវធ្វើដូចម្ដេចទៅ.?

ដូចដែលសាស្ត្រាចារ្យយ៉ាម៉ាម៉ូតូអ៊ីសូរ៉ូគឺ បានសរសេរដែរថា ត្រូវពន្យល់ឱ្យធ្វើតាមពាក្យយើងឱ្យគេសាកលមើលឬបង្ហាញជាគម្រូឬសរសើរ។ពោលគឺថាមុននឹងស្ដីបន្ទោស ត្រូវបង្ហាញគម្រូឱ្យឃើញជាមុនហើយបើកូននោះធ្វើតាមបាន ត្រូវសរសើរគេ។បើអាចធ្វើដូច្នេះបាននឹងអាចកម្រើកបេះដូងរបស់ដៃគូបាន។សូមបញ្ជាក់ថានៅឃ្លាបញ្ចប់មានសរសេរថា៖”នៅពេលដែលដៃគូគេកំពុងតែធ្វើអ្វីដែលយើងបានប្រាប់គេឱ្យធ្វើ យើងត្រូវតែតាមមើលទង្វើគេដោយអំណរគុណ។មនុស្សយើងទាល់តែមានគេជឿទុកចិត្តទើបធ្វើអ្វីៗបានសម្រេច។”ពិតណាស់ទង្វើនេះសំខាន់ណាស់ពោលគឺជឿថាដៃគូមានធាតុព្រះពុទ្ធហើយគោរពធាតុព្រះពុទ្ធនោះ។ម្យ៉ាងទៀតនៅក្នុងទង្វើដោយអំណរគុណនេះក៏ធ្វើឱ្យដៃគូយល់បានពីគំនិតយើងដែរថា”ខ្ញុំត្រូវការអ្នក ខ្ញុំខ្វះអ្នកមិនបានទេ”ដែលជាន័យសេចក្ដីស្នេហានិងការជឿទុកចិត្តចំពោះដៃគូផងដែរដែលធ្វើឱ្យគាត់ចាប់ភ្លឹកពីតម្លៃរបស់ខ្លួនគាត់ហើយមានសេចក្ដីសប្បាយរីករាយនឹងរស់នៅព្រមទាំងនាំឱ្យសេចក្ដីក្លាហានផុសចេញមកផង។ជាមួយនឹងគ្នានេះដែរទាញទឹកចិត្តមួយឱ្យគិតថា”ខ្ញុំក៏ចង់ឱ្យបានទៅជាដូចអ្នកហ្នឹងដែរ។”

មានលោកម្នាក់ដែលធ្លាប់ធ្វើជាប្រធានព្រះវិហារមួយបានមានប្រសាសន៍ថា«នៅពេលដែលស្ដាប់រឿងផ្ទាល់ខ្លួនរបស់បរិស័ទម្នាក់ពួកគេបានសរសើរពួកគេ ខ្ញុំរបស់រឿងជាកុសលពីទទួលបានខ្ញុំដែលអ្វីនូវគេវិញប្រាប់ហើយដើម្បី»។ កត្តានេះបង្រៀនយើងនូវមេរៀនសំខាន់មួយថាយើងអាចសរសើរអ្នកដទៃបានលុះត្រាតែបេះដូងយើងស្មោះត្រង់ឬបានបទ ហើយគោរពពួកគេដោយជឿលើធាតុព្រះពុទ្ធរបស់គេ។

ព្រះករុណាអាត្មាភាពយល់ថាសេចក្ដីព្យាយាមជារៀងរាល់ថ្ងៃអាចបណ្ដុះបណ្ដាលមនុស្សផងអាចអភិវឌ្ឍខ្លួនយើងឱ្យកាន់តែល្អិតលាស់ក្នុងភាពជាមនុស្សផងហើយព្រះពុទ្ធក៏លោកច្បាស់ជានឹងលើកទឹកចិត្តយើងហើយសរសើរយើងផងដែរ។

“កូសេ” លេខខែ៨ ឆ្នាំ២០២៥






# A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp